# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ៤១១,១៥៧ ដុល្លារអាមេរិក សម្រាប់គម្រោងនៅសាលាចំនួនបី



ក្រោមគ្រោងការណ៍ នៃ កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច របស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន៤១១,១៥៧ដុល្លាអាមេរិកដល់ស្ថាប័នទទួលជំនួយចំនួន៣។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងតំណាងស្ថាប័នទទួលជំនួយទាំង៣សម្រាប់គម្រោងដូចតទៅ៖

<u>១. គម្រោងសាងសង់អគារសិក្សានៅសាលាបឋមសិក្សាប៉ោយអង្គរ និងសាលាបឋមសិក្សាខ្នាយ ក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ (៩៧,៤៣១ដុល្លាអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ អង្គការសាម៉ារីតាន់ ភឺស (សង្គ្រោះ អន្តរជាតិ)</u>



អគារសិក្សាដែលបាក់បែកទ្រុឌទ្រោម



ការប្រើប្រាស់ឃ្លាំងស្រូវជាថ្នាក់រៀន

គម្រោងនេះគឺដើម្បីសាងសង់អគារសិក្សា និងបំពាក់គ្រឿងសង្ហារឹមក្នុងសាលាបឋមសិក្សាប៉ោយអង្គរ និង សាលាបឋមសិក្សាខ្នាយ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ជាមួយនឹងគម្រោងនេះ យើងសង្ឃឹមថា សិស្សានុសិស្ស ប្រមាណ ជាង ៣៩០នាក់ នៃសាលាបឋមសិក្សាទាំងពីរនឹងរីករាយជាមួយការសិក្សាក្នុងបរិស្ថានអប់រំដែលត្រូវបានកែលម្អនេះ។

<u>២. គម្រោងសាងសង់សាងសង់អគារសិក្សានៅអនុវិទ្យាល័យភ្នំធំ ក្នុងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ (១០៧,០៧៨ដុល្លាអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ អនុវិទ្យាល័យភ្នំធំ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ</u>

គម្រោងនេះគឺដើម្បីសាងសង់អគារសិក្សាពីរខ្នងនៅអនុវិទ្យាល័យភ្នំធំ ក្នុងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។ តាមរយៈគម្រោងនេះ សិស្សានុសិស្សប្រមាណជាង៦៧០នាក់នឹងអាចសិក្សាក្នុងថ្នាក់រៀនដែលមានសុវត្ថិភាព និងប្រកបដោយផាសុខភាព។





ដំបូលនៃអគារចាស់មួយដែលត្រូវបានប្រក់ជាឡើងវិញ

**៣.  គម្រោងសាងសង់អគារសិក្សានៅសាលាបឋមសិក្សាអង្គរអង្គ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង (១០៣,៨២៤ដុល្លាអាមេរិក)**
**ស្ថាប័នទទួលជំនួយ៖ ការិយាល័យអប់រំ យុវជន និងកីឡាស្រុកកំពង់ត្របែក ខេត្តព្រៃវែង**

គម្រោងនេះគឺដើម្បីសាងសង់អគារសិក្សាដែលមានកម្ពស់ខ្ពស់មួយខ្នងដោយមានបំពាក់សង្ហារឹម និងបរិក្ខារអនាម័យនៅសាលាបឋមសិក្សាអង្គរអង្គ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ តាមរយៈគម្រោងនេះ សិស្សានុសិស្ស ប្រមាណជាង២០០នាក់នឹងរីករាយជាមួយការសិក្សាក្នុងថ្នាក់រៀនដែលមានសុវត្ថិភាពនិងប្រកបដោយផាសុខភាព។


គ្រឹះអគារត្រូវបានបំផ្លាញដោយទឹកជំនន់


ថ្នាក់រៀនមួយចំនួនត្រូវបានបិទដើម្បីសុវត្ថិភាព

**៤. គម្រោងសាងសង់អគារសិក្សានៅអនុវិទ្យាល័យតាកែវ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (១០២,៨២៤ដុល្លាអាមេរិក)**
**ស្ថាប័នទទួលជំនួយ៖ ការិយាល័យអប់រំ យុវជន និង កីឡាស្រុកកំពង់ត្របែក ខេត្តព្រៃវែង**

គម្រោងនេះគឺដើម្បីសាងសង់អគារសិក្សាដែលមានកម្ពស់ខ្ពស់មួយខ្នងដោយមានបំពាក់សង្ហារឹម និងបរិក្ខារអនាម័យនៅអនុវិទ្យាល័យតាកែវ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ តាមរយៈគម្រោងនេះ សិស្សានុសិស្ស ប្រមាណ ១២០ នាក់ នឹង រីករាយជាមួយការសិក្សាក្នុងបរិស្ថានអប់រំដែលត្រូវបានកែលម្អនេះ។

ជំនួយ *គូសាណូណេ* របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង ភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការ ចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជា ជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៩.៩លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួ ន៤៩៩ គម្រោង នៅទូទាំង ប្រទេស។



*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*